ផលិតផលនោះ។ ផលិតផលសំគាល់ភូមិសាស្ត្រអាចចាត់ទុកថាជា " **ផ្លាកសញ្ញាដែនដី** "។

## គំរោងនាំមុខសំរាប់ការពារផលិតផលសំគាល់ភូមិសាស្ត្រ នៅកម្ពុជា

ជាគំរោងមួយរបស់ក្រសួងពាណិជ្ជកម្មដោយសហការណ៍ជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ គំរោងនេះទទួលមូនិធិពីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD) និងជំនួយបច្ចេកទេសពីអង្គការហ្គ្រេត (GRET : ក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកទេស) និង អង្គការស៊ីដ (CIRD : វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជនបទកម្ពុជា)។ គំរោងមានរយៈ ពេល ២ ឆ្នាំកន្លះ ដោយគិតចាប់ពីខែមិថុនា ឆ្នាំ ២០០៧ ដល់ ខែ ធ្នូ ឆ្នាំ ២០០៩ ដោយសាកល្បងអនុវត្តលើផលិតផល សំគាល់ភូមិសាស្ត្រ នាំមុខចំនួន ២ មុខ គឺ ស្ករត្នោតកំពង់ស្ពឺ និង ម្រេចកំពត នៅក្នុងចំណោមផលិតផលសក្តានុពលជាច្រើនទៀតដែលមាននៅក្នុងប្រទេសកម្ពុជា។

គោលបំណងសំខាន់របស់គំរោងគឺ ជួយរៀបចំឱ្យមានការចុះបញ្ជីកាពារផលិតផលសំគាល់ភូមិសាស្ត្ររបស់ផលិតករ ពាណិជ្ជករ និងអ្នកពាក់ព័ន្ធដទៃទៀតក្រោមច្បាប់ការពារម៉ាកសំរាប់ការសំគាល់ភូមិសាស្ត្រទំនិញដើម្បីការពារទល់នឹងការក្លែងបន្លំសំដៅលើកតំលៃ និង កេរ្តិ៍ឈ្មោះផលិតផលពិតប្រាកដ ការពារអ្នកបរិភោគ និង បង្កើនប្រាក់ចំណូលដល់ផលិតករជនបទ។

## ព័ត៌មានបន្ថែមសូមទាក់ទង


**ក្រសួងពាណិជ្ជកម្ម (MoC)**
លោក ឡៅ រាសី - LAO Reasey
ទូរស័ព្ទ/Tel : ០១២ ៨០៧ ៣៤៦
E-mail: reasey_pp34@yahoo.com

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)**
លោក អំ ភិរម្យ - AM Phirum
ទូរស័ព្ទ/Tel : ០១១ ៩២៧ ៨៦២
E-mail: amphirum@yahoo.com

**អង្គការស៊ីដ (CIRD)**
លោក ប្រាក់ សេរីវឌ្ឍន៍ - PRAK Sereyvath
ទូរស័ព្ទ/Tel : ០១២ ៨៨៧ ៩៦៦
E-mail: praksereyvath@online.com.kh

**អង្គការហ្គ្រេត (GRET)**
លោក ហ្សង់ម៉ារី ប្រេង - Jean-Marie BRUN
ទូរស័ព្ទ/ Tel : ០១២ ៨០៧ ៨១៧
E-mail: brun@gret.org




# ផលិតផលសំគាល់ភូមិសាស្ត្រ

## Geographical Indication Products

## ការពារ "ផ្លាកសញ្ញាដែនដី" ដើម្បីផលប្រយោជន៍របស់ផលិតករជនបទ



AGENCE FRANÇAISE DE DÉVELOPPEMENT

GRET

Cambodian Institute for Research and Rural Development

## អ្វីទៅជាផលិតផលសំគាល់ភូមិសាស្ត្រ?

ផលិតផលសំគាល់ភូមិសាស្ត្រគឺជាផលិតផលដែលមានលក្ខណៈពិសេសដោយឡែក ដោយផ្សារភ្ជាប់ទៅនឹងដែនដី អាកាសធាតុ ស្នាដៃ បច្ចេកទេស និង ទេពកោសល្យរបស់ប្រជាកសិករនៃតំបន់ជាក់លាក់មួយ ។ លក្ខណៈពិសេសនៃផលិតផលទាំងនោះនាំឱ្យមានកិត្តិស័ព្ទល្បីល្បាញនៅលើទីផ្សារ ឬត្រូវបានគេទទួលស្គាល់និងឱ្យតំលៃតាំងពីយូរយាណាស់មកហើយ ។ ជាឧទាហរណ៍ នៅប្រទេសកម្ពុជា យើងមានផលិតមួយចំនួនដែលជា ផលិតផលសំគាល់ភូមិសាស្ត្រ ដូចជា: ម្រេចកំពត ធូរេនកំពត ក្រូចពោធិ-សាត់បាត់ដំបង អង្ករបាត់ដំបង ស្ករត្នោតកំពង់ស្ពឺ សូត្រខ្មែរភ្នំស្រុក ប្រហុកសៀមរាប ក្រវាញពោធិ៍សាត់ ក្រូចថ្លុងក្រចេះ ក្រឡានក្រចេះ និងផលិតផលផ្សេងៗទៀត ។ ផលិតផលទាំងនេះអាចផលិត ឬដាំបាននៅទីកន្លែងដទៃទៀត ប៉ុន្តែវាពុំមានគុណភាពឬលក្ខណៈដូចគ្នាទៅនឹងផលិតផលដែលបានរៀបរាប់ខាងលើ នោះទេ ។ ឧទាហរណ៍ លក្ខណៈពិសេសដោយឡែកនៃម្រេចកំពតគឺ:

*"ម្រេចកំពត ជាប្រភេទម្រេចដែលមានក្លិន និងមានរសជាតិហិរពិសេសខុសប្លែកពីម្រេចនៅតំបន់ដទៃទៀតនៅប្រទេសកម្ពុជា ។ លក្ខណៈ និងគុណភាពដ៏ល្អពិសេសប្លែកគេរបស់ ម្រេចកំពត កើតចេញពីស្នាដៃ បច្ចេកទេស និងទេពកោសល្យរបស់ប្រជាកសិករដែលបានច្នៃប្រឌិតជាច្រើនជំនាន់ គួបផ្សំជាមួយឥទ្ធិពលនៃ ដី ភ្នំ សមុទ្រ និងលក្ខណៈអាកាសធាតុនៅក្នុងតំបន់នោះ"* ។



ម្រេចកំពត



- ផលិតផលសំគាល់ភូមិសាស្ត្រ មានឈ្មោះល្បីដែលគេស្គាល់ជាទូទៅនៅលើទីផ្សារៈ ការស្គាល់ ឬល្បីឈ្មោះនៅលើទីផ្សារ បញ្ជាក់អំពីកិត្តិស័ព្ទរបស់ផលិតផល ។
- ឈ្មោះផលិតផលត្រូវបញ្ជាក់ពីគុណភាពពិសេសដោយឡែករបស់វា ។ អាចនិយាយម្យ៉ាងទៀតបានថា រូបភាព ពណ៌ រសជាតិ លក្ខណៈរូប-គីមី វត្ថុធាតុដើម គឺជាចំនុចដែលបញ្ជាក់ពីលក្ខណៈពិសេសរបស់ផលិតផលនិមួយៗ ។
- ជាចុងក្រោយ ឈ្មោះនិងគុណភាពពិសេសដោយឡែករបស់ផលិតផលត្រូវតែផ្សារភ្ជាប់ជាមួយនឹងដែនដីដែលគេផលិតផលិតផលនោះ ។ ដែនដីផ្តល់លក្ខណៈពិសេសដល់ផលិតផលតាមរយៈលក្ខណៈផ្ទាល់របស់ដែនដី( លក្ខណៈឬ គុណភាពដី អាកាសធាតុ...) ឬតាមរយៈភាពជំនាញរបស់ផលិតករដែលបានច្នៃប្រឌិត និងកែលំអកន្លងមក ។

បច្ចុប្បន្ននេះផលិតផលសំគាល់ភូមិសាស្ត្រ ត្រូវបានទទួលស្គាល់ដោយអង្គការពាណិជ្ជកម្មពិភពលោក ។ ដូច្នេះនេះ គឺជាជំរើសមួយសំរាប់ប្រទេសកម្ពុជាដែលជាសមាជិកក្នុងការរៀបចំនីតិវិធីចុះបញ្ជីការពារផលិតផលសំគាល់ភូមិសាស្ត្រថ្នាក់ជាតិ ដើម្បីការពារផលិតករទប់ទល់នឹងការដណ្តើមសិទ្ធិ និង ការក្លែងបន្លំ ។

## ការការពារផលិតផលសំគាល់ភូមិសាស្ត្រ

ប្រទេសកម្ពុជាយើងកំពុងរៀបចំច្បាប់ស្តីអំពី ការសំគាល់ភូមិសាស្ត្រផលិតផល ដែលច្បាប់នេះនឹងជួយការពារផលិតផលសំគាល់ភូមិសាស្ត្រ ប្រយោជន៍ដើម្បីៈ

- **ការពារអតិថិជន ឬអ្នកប្រើប្រាស់:** កុំអោយអតិថិជន ឬអ្នកប្រើប្រាស់ភាន់ច្រឡំអំពីកិត្តិស័ព្ទ និងគុណភាពរបស់ផលិត-ផលនៅលើទីផ្សារ ។ ប្រសិនបើឈ្មោះផលិតផលត្រូវបានគេក្លែងបន្លំ វានឹងនាំអោយអតិថិជនដែលជាអ្នកប្រើប្រាស់ ឬអ្នកបរិភោគ មានការភាន់ច្រឡំលើផលិតផលពិតប្រាកដដែលគេចង់បាន ។
- **ការពារផលិតករ:** គុណភាពពិសេសដោយឡែកនៃ ផលិតផលសំគាល់ភូមិសាស្ត្រ នាំឱ្យផលិតផលមានតំលៃខ្ពស់ជាងផលិតផលធម្មតា ។ ការការពារពីការក្លែងបន្លំ នឹងមិនធ្វើឱ្យខូចកិត្តិស័ព្ទព្រមទាំងអាចលើកតំលៃផលិតផលពិតប្រាកដ ដែលជាការនាំមកនូវផលប្រយោជន៍សំរាប់ផលិតករដែលជាអ្នកផលិតផលិតផលសំគាល់ភូមិសាស្ត្រ ។

ការការពារផលិតផលសំគាល់ភូមិសាស្ត្រ គឺជាការការពារកម្មសិទ្ធិបញ្ញានៃក្រុមមនុស្សដែលរស់នៅលើដែនដីនៃ